**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/០២/០៧-០៩-២០០៩-អវតក/កសចស
**ដាក់ទៅ** : សហចៅក្រមស៊ើបអង្កេត
**ថ្ងៃដាក់** : ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 21-Dec-2016, 15:15
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សម្ងាត់** អមដោយ **ឧបសម្ពន្ធសម្ងាត់ជប់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:** សម្ងាត់/Confidential

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និង សម្ភារៈនៃសំណុំរឿង០០២ នៅក្នុងសំណុំរឿង០០៤/០២**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | |
|---|---|---|
| **សហព្រះរាជអាជ្ញាអន្តរជាតិ** | **សហចៅក្រមស៊ើបអង្កេត** | **សហមេធាវី អោ អាន:** |
| Nicholas KOUMJIAN | ចៅក្រម យូ ប៊ុនឡេង | មុំ លុជ្ស |
| | ចៅក្រម Michael BOHLANDER | Richard ROGERS |
| **ចម្លងជូន:** | | Göran SLUITER |
| **សហព្រះរាជអាជ្ញាជាតិ** | **មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | |
| ជា លាង | **នៃសំណុំរឿង០០៤/០២ ទាំងអស់** | |

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ("សហព្រះរាជអាជ្ញា") សូមស្នើសហចៅក្រមស៊ើបអង្កេត("សចស") ដាក់សម្ភារៈទៅក្នុងសំណុំរឿង០០៤/២ ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងកិច្ចស៊ើបសួរលើ អោ អាន។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើនេះគឺមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ និងពន្យល់អំពីមូលហេតុដែលកិច្ចស៊ើបសួរនេះចាំបាច់សម្រាប់ធ្វើការស៊ើបអង្កេត។[1]

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ និងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") បានជូនដំណឹងដល់ អោ អាន ថាមានភស្តុតាងច្បាស់លាស់ និងស្របគ្នាថាគាត់អាចមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តឡើងនៅភូមិភាគកណ្ដាល រួមទាំង ការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញទៅលើខ្មាំងខាងក្នុង និងអតីតទាហាន លន់ នល់ ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ចាម និងអំពើអមនុស្សធម៌ផ្សេងៗទៀត រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ។[2]

3. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ សចសអ បានណែនាំសហព្រះរាជអាជ្ញាឲ្យអនុវត្តតាមនីតិវិធីថ្មី នៅពេលដែលដាក់សំណើសុំដាក់ឯកសារសម្ងាត់ពីសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤។[3] ខណៈដែលពីមុនមក សហព្រះរាជអាជ្ញាបានផ្អែកលើអង្គហេតុដែលថាអង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យ សចស ចូលមើលឯកសារសម្ងាត់ទាំងអស់ក្នុងសំណុំរឿង០០២ នីតិវិធីដែលកែប្រែថ្មីនេះ តម្រូវឲ្យសហព្រះរាជអាជ្ញាទទួលការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់

---

[1] ដូចដែលត្រូវបានតម្រូវដោយវិធានផ្ទៃក្នុង និងអង្គបុរេជំនុំជម្រះ។ *សូមមើល* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិ. ៩), ដែលត្រូវបានពិនិត្យឡើងវិញនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥, វិធាន ៥៥(៥), ៥៥(១០) និង ៥៨(៦)។ *សំណុំរឿង០០២*-**D164/3/6** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម, ១២ វិច្ឆិកា ២០០៩, កថាខណ្ឌ៤៣។ *សំណុំរឿង០០២*-**D164/4/13** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម, ១៨ វិច្ឆិកា ២០០៩, កថាខណ្ឌ៤៤។

[2] **D242** កំណត់ហេតុនៃការស្ដាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូងរបស់លោក អោ អាន, ២៧ មិនា ២០១៥។ **D303** កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀតរបស់ អោ អាន, ១៤ មីនា ២០១៦។

[3] **D322/6** សេចក្ដីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំព័ត៌មាន និងឯកសារបន្ថែមពាក់ព័ន្ធនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សម្ភារៈស្ដីពីគោលនយោបាយរបស់ បកក ទៅក្នុងសំណុំរឿង០០៤, ១៦ កញ្ញា ២០១៦ ("សេចក្ដីសម្រេចថ្ងៃទី១៦ កញ្ញា"), កថាខណ្ឌ១២-១៤, ១៨។

បង្ហាញឯកសារសម្ងាត់នីមួយៗទៅឲ្យមេធាវីការពារក្ដីមុនពេលស្នើសុំថា សចស ដាក់ឯកសារក្នុងសំណុំរឿង។ ដើម្បីអនុវត្តតាមសេចក្តីណែនាំរបស់ សចសអ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាបានស្វែងរកការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់បង្ហាញឯកសារសម្ងាត់ដែលមានរៀបរាប់នៅក្នុងឧបសម្ពន្ធ ក ទៅមេធាវីការពារក្ដីនៃសំណុំរឿង០០៤ (អោ អាន និង យឹម ទិត្យ)។[4] ប្អូនសប្ដាហ៍ក្រោយមក នៅរសៀលថ្ងៃទី ៧ ខែធ្នូ ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ការអនុញ្ញាត។[5] ថ្ងៃបន្ទាប់ សហព្រះរាជអាជ្ញាបានដាក់បង្ហាញឯកសារសម្ងាត់ទាំងនោះទៅកាន់មេធាវីការពារក្ដីនៃសំណុំរឿង០០៤ និងបានដាក់សំណើមួយសុំបន្ថែមសម្ភារៈសម្ងាត់ និងជាសាធារណៈទៅក្នុងសំណុំរឿង០០៤ (“សំណើដើម”)។[6]

4. នៅព្រឹកបន្ទាប់ នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៦ ភាគីបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់ សចសអ បង្រួញកាលបរិច្ឆេទកំណត់សម្រាប់មេធាវីការពារក្ដីនៃសំណុំរឿង០០៤ ដើម្បីចម្លើយតបទៅនឹងសំណើដើមនោះ ដោយបានកំណត់កាលបរិច្ឆេទកំណត់ត្រឹមម៉ោង ១២ ល្ងាច នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦។[7]

---

[4] ដូចបានបញ្ជាក់ដោយចំណុច “គ” នៅក្នុងកូឡោនទីពីរនៃឧបសម្ពន្ធ ក។ សូមមើលផងដែរ សំណុំរឿង០០២-**E450** (សម្ងាត់) សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការអនុញ្ញាតដើម្បីផ្តល់ឯកសារសម្ងាត់នៃសំណុំរឿង០០២ ដល់ក្រុមមេធាវីការពារក្ដីនៃសំណុំរឿង០០៤, ១១ វិច្ឆិកា ២០១៦។

[5] សំណុំរឿង០០២-**E450/1** (សម្ងាត់) អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា “សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការអនុញ្ញាតដើម្បីផ្តល់ឯកសារសម្ងាត់ក្នុងសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤ ដល់ក្រុមមេធាវីការពារក្ដី” ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៦ បានជូនដំណឹងនៅម៉ោង ៤:៣៤ ល្ងាច (អ៊ីម៉ែលនៃសេចក្តីជូនដំណឹងនេះត្រូវបានភ្ជាប់ជា**ឧបសម្ពន្ធ ១**)។

[6] ឯកសារទាំងនោះត្រូវបានដាក់បង្ហាញតាមរយៈការភ្ជាប់ (link) ដែលបានផ្ញើក្នុងសារអ៊ីម៉ែលពីជំនួយការសហព្រះរាជអាជ្ញា នៃ កសព ទៅកាន់ក្រុមមេធាវីការពារក្តី អោ អាន និង យឹម ទិត្យ នៅម៉ោង ១០:០៥ ព្រឹក នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ (សូមមើល **ឧបសម្ពន្ធ ២**)។ សំណើទៅកាន់ កសចស ត្រូវបានដាក់នៅម៉ោង ១:១៨ ល្ងាច ជាឯកសារ **D333** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងសម្ភារៈនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤ (សូមមើលទម្រង់បែបបទស្ដីពីការដាក់ឯកសារ ភ្ជាប់ជា**ឧបសម្ពន្ធ ៣**)។ សំណើត្រូវបានជូនដំណឹងទៅកាន់ភាគីនៅថ្ងៃបន្ទាប់នៅម៉ោង ១១:២៦ ព្រឹក។

[7] សូមមើល អ៊ីម៉ែល ពី មន្ត្រីផ្នែកច្បាប់របស់ កសចស ទៅកាន់ភាគី ផ្ញើនៅថ្ងៃទី៩ ធ្នូ ២០១៦ នៅម៉ោង ១០:៣៦ ព្រឹក (ភ្ជាប់ជា **ឧបសម្ពន្ធ ៤**)។

5. នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ មេធាវីការពារក្តី យឹម ទិត្យ បានស្នើសុំតាមរយៈអ៊ីម៉ែលសុំឲ្យផ្តល់ជូនពេលចំនួន ១០ ថ្ងៃពេញ គឺរហូតដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីដាក់ចម្លើយតបទៅនឹងសំណើដើមនេះ។[8] សចសអ បានបដិសេធសំណើនោះ។[9] ដូចគ្នានេះដែរ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ មេធាវីការពារក្តី អោ អាន បានដាក់ជាផ្លូវការនូវសំណើសុំទទួលបានពេល ១០ ថ្ងៃពេញដើម្បីដាក់ចម្លើយតប។[10]

6. ក្រោយមក នៅរសៀលថ្ងៃនោះ សហព្រះរាជអាជ្ញាបានជម្រាប សចស និងភាគីនៃណុំរឿង០០៤ ថា ខ្លួននឹងដកយកសំណើដើម និងដាក់ជូនទៅវិញក្នុងរយៈកាល១៥ថ្ងៃ ដែលបានអនុញ្ញាតនៅក្រោមវិធាន៦៦(១) ដើម្បីស្នើសុំនូវកិច្ចស៊ើបសួរបន្ថែមនៅក្រោយពេលបិទកិច្ចស៊ើបសួរ ដែលតាមហេតុការណ៍នេះ បានអនុញ្ញាតឲ្យមេធាវីការពារក្តីនូវពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតបឲ្យបានពេញលេញ។[11] សេចក្តីជូនដំណឹងស្តីពីការដកចេញជាផ្លូវការ ត្រូវបានដាក់ជូននៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦[12] និងបានជូនដំណឹងដល់ភាគីនានានៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦។

7. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន[13] និងបានបំបែកកិច្ចដំណើរការនីតិវិធីលើ អោ អាន ចេញពីកិច្ចស៊ើបសួរលើ យឹម ទិត្យ

---

[8] សូមមើល អ៊ីម៉ែល ពី Marija Brackovic ផ្ញើថ្ងៃទី១២ ធ្នូ ២០១៦ នៅម៉ោង ១:៣៤ល្ងាច (ភ្ជាប់ជា **ឧបសម្ពន្ធ ៥**)។

[9] សូមមើល អ៊ីម៉ែល ពី មន្ត្រីផ្នែកច្បាប់របស់ កសចស ទៅកាន់ភាគី ផ្ញើនៅថ្ងៃទី ១២ ធ្នូ ២០១៦ នៅម៉ោង ២:០៥ ល្ងាច (ភ្ជាប់ជា **ឧបសម្ពន្ធ ៦**)។

[10] **D333/1** ញត្តិសុំឲ្យពិចារណាឡើងវិញនូវដីកាសម្រេចលើការដាក់ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងសម្ភារៈនៃសំណុំរឿង០០២ ទៅក្នុងសំណុំរឿង០០៤, ១២ ធ្នូ ២០១៦។

[11] សូមអានអ៊ីមែលពីជំនួយការសហព្រះរាជអាជ្ញានៃ កសព ដែលបានផ្ញើចេញនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ នៅម៉ោង ៤:១៥ ល្ងាច (បានភ្ជាប់ជា**ឧបសម្ព័ន្ធ ៧**)។

[12] **D333/2** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការដកសំណើសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងសម្ភារៈនៃសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤ (D333), ១៣ ធ្នូ ២០១៦, បានដាក់នៅម៉ោង ១៣:៤៧ ល្ងាច (សូមមើលទម្រង់នៃការដាក់ឯកសារ, បានភ្ជាប់ជា**ឧបសម្ព័ន្ធ ៨**)។

[13] **D334** សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន, ១៦ ធ្នូ ២០១៦ ("សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ")។

បង្កើតបានជាសំណុំរឿង០០៤/២ សម្រាប់កិច្ចដំណើរការនីតិវិធីលើ អោ អាន[14] និងផ្ដល់រយៈពេលចំនួន ១៥ថ្ងៃ សម្រាប់ភាគីនានាដាក់សំណើបន្ថែមទាំងឡាយសម្រាប់កិច្ចស៊ើបសួរ។[15]

8. នៅពេលនេះ សហព្រះរាជអាជ្ញា ដាក់សារជាថ្មីម្ដងទៀតនូវសំណោកាត់បន្ថយនៃសំណើនោះដោយអនុលោមតាមវិធាន៦៦(១)។ សំណើដើមត្រូវបានកែតម្រូវ ជាពិសេស ដោយការដកយកឯកសារទាំងឡាយ ដែលសហព្រះរាជអាជ្ញាយល់ឃើញថា ទាក់ទងតែទៅនឹងកិច្ចស៊ើបសួរលើ យឹម ទិត្យ ប៉ុណ្ណោះ ដែលវាលែងទៅជាផ្នែកនៃសំណុំរឿងរបស់ អោ អាន ទៀតហើយ និងដោយការដកយកឯកសារដែលត្រូវបានបន្ថែមដោយ សចសអ *តាមការយល់ឃើញរបស់ខ្លួន* ទៅក្នុងសំណុំរឿង បន្ទាប់ពីការដាក់សំណើដើម។[16]

## III. សំណើ

9. សហព្រះរាជអាជ្ញាសូមស្នើឲ្យ សចស ដាក់ផែនទី ឯកសារនៃសំណុំរឿង០០២ និងខ្សែវីដេអូ (រួមគ្នាហៅថា"សម្ភារៈ") ទៅក្នុងសំណុំរឿង០០៤/០២ ដូចបានកំណត់អត្តសញ្ញាណ និងរៀបរាប់ដោយសង្ខេបនៅទីនេះ និងយ៉ាងលម្អិតនៅក្នុងឧបសម្ព័ន្ធ ក។ សម្ភារៈទាំងអស់នឹងនាំទៅដល់ការបញ្ជាក់អំពីការពិត និងមានការពាក់ព័ន្ធដោយផ្ទាល់ទៅក្នុងកិច្ចស៊ើបសួរលើ អោ អាន ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្ដាល ឬជួយក្នុងការបង្ហាញឲ្យឃើញថាឧក្រិដ្ឋកម្មទាំងនេះ គឺជាផ្នែកនៃការវាយប្រហារយ៉ាងរីករាលដាល និងជាប្រព័ន្ធប្រឆាំងជនស៊ីវិល។

### *ឯកសារគោលនយោបាយជាតិ*

10. *ឯកសារ ទី១* គឺជាកូនសៀវភៅដែលមាន៦ទំព័រ ដែលបានបោះពុម្ពផ្សាយដោយក្រសួងអប់រំ ពន្យល់ពីការបែងចែកនៃការរៀបចំនៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងបង្ហាញពីរចនាសម្ព័ន្ធឋានានុក្រម និងការប្រព្រឹត្តទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ។

11. *ឯកសារ ទី២* គឺជារបាយការណ៍សារព័ត៌មានថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ នៃសុន្ទរកថារបស់ ខៀវ សំផន ក្នុងពិធីគម្រប់ខួប ដែលនៅក្នុងសុន្ទរកថានោះ គាត់បានពិភាក្សាអំពីបញ្ហាផ្សេងៗ ដែល

---

[14] **D334/1** ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤, ១៦ ធ្នូ ២០១៦។

[15] **D334** សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ, កថាខណ្ឌ ៦។

[16] សូមមើលអ៊ីមែលពីចៅក្រម Bohlander ដែលផ្ញើចេញនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ នៅម៉ោង ១១:២៨ ព្រឹក (**ឧបសម្ព័ន្ធ ៩**)។

ក្នុងចំណោមនោះ មានកិច្ចប្រឹងប្រែងកសាងជាតិ និងគោលនយោបាយ បកក ប្រឆាំងវៀតណាម។ របាយការណ៍សារព័ត៌មាននេះ ក៏ធ្វើសង្ខេបអំពីដំណោះស្រាយផ្សេងៗដែលបានអនុម័តដោយបក្ស ទាក់ទងនឹងទិសដៅនៃការបង្កបង្កើនផលកសិកម្មសម្រាប់ឆ្នាំ១៩៧៨ ដែលត្រូវសម្រេចឲ្យបានទោះ "ក្នុងតម្លៃណាក៏ដោយ" និងអំពីតម្រូវការក្នុងការបង្កើនចំនួនប្រជាជន។ សុន្ទរកថានេះ និងការបោះពុម្ពផ្សាយដំណោះស្រាយ គឺជាឧទាហរណ៍នៃការផ្សាយផ្សាយគោលនយោបាយ បកក ដែលបន្ទាប់មកត្រូវបានគេយកទៅអនុវត្តនៅមូលដ្ឋាន ហើយគឺជាបញ្ហាដ៏សំខាន់ដែលត្រូវមានជាកំណត់ហេតុមួយអំពីឱកាសជាច្រើនដែលមេដឹកនាំបក្ស បានបញ្ជូនសេចក្តីណែនាំផ្សេងៗដូច្នេះទៅឲ្យមហាជន។

12. ពាក់ព័ន្ធនឹង ខៀវ សំផន ផងដែរគឺ *សម្ភារៈ ទី៣ និង ទី៤* ដែលជាសម្រង់នៃខ្សែវីដេអូនៃបទសម្ភាសន៍ និងប្រតិចារឹកដែលឆ្លើយតបទៅនឹងបទសម្ភាសន៍នោះ ដែលក្នុងនោះ ខៀវ សំផន ពិភាក្សាពីភាពលេចធ្លោររបស់ តា ម៉ុក នៅក្នុង បកក និងភាពសំខាន់របស់គាត់ចំពោះ ប៉ុល ពត ព្រមទាំងលក្ខណៈបង្ខិតបង្ខំក្នុងសហករណ៍។ ភ័ស្តុតាងនេះ មានសារៈសំខាន់ណាស់សម្រាប់ការយល់ដឹងអំពីរបៀបដែល តា ម៉ុក បានដាក់ការងារដល់អ្នកនៅក្រោមបង្គាប់របស់គាត់ ដូចជា អោ អាន ជាដើម ដែលជាអ្នកអនុវត្តគោលនយោបាយរបស់ បកក និងដើម្បីបង្ហាញឲ្យឃើញថាការបង្គាប់និងការបង្ខិតបង្ខំទាំងនោះ ត្រូវបានគេយល់ថាជាប់ជាមួយនឹងគោលនយោបាយរបស់ បកក ទាំងនោះ ហើយមានចេតនា និងបានទទួលយកដោយមេដឹកនាំជាន់ខ្ពស់ទៀតផង។

## *ប្រតិចារឹកសវនាការសំណុំរឿង០០២/០២*

13. មានប្រតិចារឹកសវនាការពីរប្រភេទដែលមាននៅក្នុងឧបសម្ព័ន្ធ ក។ ប្រភេទទីមួយ ត្រូវបានបញ្ចប់ហើយត្រូវបានដាក់លេខសំណុំរឿង០០២ រួចហើយ ដោយផ្តើមជាមួយនឹង E1/បុព្វបទ (*សម្ភារៈ ទី៥-៧ និងមួយផ្នែកនៃសម្ភារៈ ទី៨-៩*)។ ប្រភេទទីពីរនៃប្រតិចារឹក អាចរកបានតែក្នុងទម្រង់នៃសេចក្តីព្រាងសម្ងាត់ប៉ុណ្ណោះ ដោយសារកំពុងតែបញ្ចប់ដោយអង្គភាពបកប្រែ (*សម្ភារៈ ទី១០-១៣ និងចំណែកដែលនៅសេសសល់នៃសម្ភារៈ ទី៨-៩*)។ ដោយមានការគិតគូរអំពីឧបសគ្គនៃពេលវេលាដែលកើតឡើងដោយសារការបិទកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាសូមស្នើថា ប្រតិចារឹកក្នុងទម្រង់ជាសេចក្តីព្រាងទាំងនេះ គួរត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់ជាគោលបំណងពិនិត្យមើល ប៉ុន្តែប្រតិចារឹកចុងក្រោយនឹងត្រូវដាក់ទៅក្នុងសំណុំរឿងនៅពេលណាអាចរកបាន។

14. មូលហេតុជាក់លាក់ដែលធ្វើឱ្យប្រតិចារឹកសាក្សីសវនាការត្រូវបានស្នើឡើង មាននិយាយលម្អិតនៅក្នុងឧបសម្ព័ន្ធ ក ប៉ុន្តែជាទូទៅ ប្រតិចារឹកទាំងនេះមានផ្ទុកនូវភ័ស្តុតាងពីអ្នកជំនាញ និងសាក្សីនានាដែលមានកំណត់ហេតុ ឬភ័ស្តុតាងផ្សេងទៀតនៅលើសំណុំរឿង០០៤/២ រួចហើយ និងសក្ខីកម្មរបស់ពួកគាត់បំពេញបន្ថែមទៅលើភ័ស្តុតាងទាំងនោះ ឬអនុញ្ញាតឱ្យយើងបានយល់កាន់តែប្រសើរចំពោះភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង។ ប្រតិចារឹកដែលបានស្នើឡើងចំនួនពីរឈុត គឺបានមកក្នុងឆ្នាំ២០១៥ និងផ្នែកដែលនៅសល់បានមកពីសីហា ដល់ខែតុលា នៃឆ្នាំនេះ។ ប្រតិចារឹកទាំងពីរឈុតនេះសុទ្ធតែចេញពីសវនាការជាសាធារណៈ ដែលភាគីនានាអាចតាមដានក្នុងពេលដែលកិច្ចដំណើរការនិតិវិធីទាំងនេះបានប្រព្រឹត្តធ្វើឡើង។

*ផែនទី*

15. សហព្រះរាជអាជ្ញាសូមស្នើដាក់បញ្ចូលផែនទីដូចបានចុះបញ្ជីក្នុងឧសបម្ព័ន្ធ ក *(សម្ភារៈ ទី១៤-២២)* ទៅក្នុងសំណុំរឿងដើម្បីជួយក្នុងការបង្ហាញ និងយល់ដឹងអំពីទីតាំងនៃឧក្រិដ្ឋកម្មទាំងនេះ ពីលក្ខណៈរីករាលដាល និងជាប្រព័ន្ធរបស់វា ផ្លូវនៃការផ្លាស់ទីលំនៅដោយបង្ខំ ពីភាពជាប់ពាក់ព័ន្ធរបស់ អោ អាន និងអ្នកនៅក្រោមបង្គាប់របស់គាត់ទៅនឹងឧក្រិដ្ឋកម្មទាំងនោះ និងអំពីព្រំប្រទល់នៃឃុំ ស្រុក តំបន់ និងភូមិភាគនានាដែលពាក់ព័ន្ធ។

*សេចក្តីពិចារណាផ្សេងទៀត*

16. សហព្រះរាជអាជ្ញា មានការគិតគូអំពីភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង០០៤/២ រួចហើយ និងបានព្យាយាមជៀសវាងធ្វើសំណើសុំឱ្យទទួលយកសម្ភារៈជាន់គ្នា។ ដូចមូលហេតុដែលបានកត់សម្គាល់ខាងលើ និងរៀបរាប់បន្ថែមក្នុងឧបសម្ព័ន្ធ ក សម្ភារៈដែលបានស្នើសុំផ្តល់នូវសេចក្តីលម្អិតទាំងឡាយដែលមិនទាន់មាននៅក្នុងសំណុំរឿង ឬមានសារៈសំខាន់ខ្លាំង សម្រាប់ការយល់ដឹងឱ្យកាន់តែច្បាស់ថែមទៀតអំពីភ័ស្តុតាងដែលមាននៅទីនោះស្រាប់។

17. សំណើនេះ មានការគោរពសិទ្ធិចំពោះការទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌របស់ អោ អាន ដោយសារនឹងមិនធ្វើឱ្យមានការពន្យារកិច្ចដំណើរការនីតិវិធីមិនត្រឹមត្រូវនោះឡើយ។[17]

[17] ដើម្បីរក្សាក្នុង *សំណុំរឿង០០២*-**D164/3/6** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម (អង្គបុរេជំនុំជម្រះ), ១២ វិច្ឆិកា ២០០៩, កថាខណ្ឌ៤៣ (កត់សម្គាល់ថា ជនត្រូវចោទ

សំណើនេះ ពាក់ព័ន្ធតែសម្ភារៈមួយចំនួនតូចដែលបានជ្រើសរើសក្នុងចំណោមឯកសារជាង ១០០០ ដែលមានតែនៅក្នុងសំណុំរឿង០០២ ប៉ុន្តែមិនមាននៅក្នុងសំណុំរឿង០០៤/២ ប៉ុណ្ណោះ។ឧបសម្ព័ន្ធ ក ផ្តល់សេចក្តីសង្ខេបខ្លីតែច្បាស់ នៃសម្ភារៈនីមួយៗ និងភាពពាក់ព័ន្ធរបស់វាក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីធានាឲ្យបានថា ការងារពិនិត្យទៅលើឯកសារទាំងនោះ នឹងមិនមែនជាបន្ទុកដល់ភាគីណាមួយ ឬ កសចស ឡើយ។

## IV. សេចក្តីសន្និដ្ឋាន

18. ការបំពេញកិច្ចដែលបានស្នើសុំ មានលក្ខណៈជាក់លាក់គ្រប់គ្រាន់ដែលអាចនាំដល់ការបញ្ជាក់អំពីការពិត ដែលចាំបាច់ចំពោះកិច្ចស៊ើបសួរ និងដោយគោរពចំពោះសិទ្ធិក្នុងការទទួលបានសវនាការមួយដែលត្រឹមត្រូវយុត្តិធម៌របស់ អោ អាន។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យដាក់សម្ភារៈទាំងនេះទៅក្នុងសំណុំរឿង០០៤/២៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

មានសិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងពេលវេលាមួយសមស្រប ដូចមានចែងនៅក្នុងមាត្រា១៤ នៃអនុញ្ញា ICCPR និងវិធាន ២១(៤) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ ឯកសារ **D322/6** សេចក្តីសម្រេចថ្ងៃទី១៦ កញ្ញា, កថាខណ្ឌ៩។